# ព្រះរាជក្រម

នស/រកម/១២០៧/០៣៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០២ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងឱសថ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការគ្រប់គ្រងឱសថ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភា លើកទី៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# វិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងឱសថ

**មាត្រាតែមួយ.-**

មាត្រា ២ មាត្រា ៤ មាត្រា ៨ មាត្រា ៩ មាត្រា ១០ មាត្រា ១១ មាត្រា ១២ និងមាត្រា ១៣ នៃច្បាប់ស្តីពីការគ្រប់គ្រងឱសថ ដែលបានប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០២ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ត្រូវធ្វើវិសោធនកម្មដូចតទៅ :

**មាត្រា ២ .- ថ្មី**

១-ឱសថសំដៅដល់សារជាតិមួយមុខ ឬ ច្រើនមុខ ដែលមានប្រភពជាអាទិ៍ពីជាតិគីមី ជីវផលិតផល ជាតិអតិសុខុមប្រាណ រុក្ខជាតិ លាយផ្សំឡើងសម្រាប់ប្រើប្រាស់ក្នុងការបង្ការ ឬ ព្យាបាលជម្ងឺមនុស្ស សត្វ ឬ ការស្រាវជ្រាវវេជ្ជសាស្ត្រ ឱសថសាស្ត្រ ឬ ធ្វើរោគវិនិច្ឆ័យ ឬ កែប្រែ ឬ ទ្រទ្រង់មុខងារនៃសរីរាង្គ ។

២-ឱសថក្លែងក្លាយ សំដៅដល់ប្រភេទឱសថ ដែលគ្មានសារជាតិសកម្ម ឬ មានសារ-ជាតិសកម្មមិនត្រឹមត្រូវ តាមរូបមន្តដែលកំណត់លើផ្លាកសញ្ញា ឬ មានសារជាតិសកម្មមិនគ្រប់ចំនួនតាមកម្រិតកំណត់លើផ្លាកសញ្ញា ឬ មានការវេចខ្ចប់ របៀបបង្ហាញរចនាបទ អត្ត-សញ្ញាណ ស្រដៀង ឬ ដូចគ្នា នឹងឱសថមួយផ្សេងទៀត ដែលជាឱសថពិត ឬ ផលិត ឬ វេចខ្ចប់ដោយគ្មានអាជ្ញាប័ណ្ណពីក្រសួងសុខាភិបាល ។

ROYAL ... PALAIS ROYAL

២-ការនាំចូល ការចែកចាយ ការតាំងលក់ឱសថ និងគ្រឿងសំអាងគ្រប់ប្រភេទក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានលេខបញ្ជិកា ពីក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

៣-ការផលិត អាហារីណ នីហារីណ និងពាណិជ្ជកម្មឱសថសម្រាប់ផ្នែកបសុពេទ្យ ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងសុខាភិបាល និងក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ ។

៤- ក្នុងគ្រឹះស្ថានផលិតឱសថ គ្រឹះស្ថាននាំចូលនិងចែកចាយឱសថ គ្រឹះស្ថានលក់ដុំឱសថ និងឱសថស្ថាន ត្រូវមានវត្តមានឱសថការី ។ ក្នុងករណីអវត្តមានឱសថការីទទួលខុសត្រូវ ត្រូវមានឱសថការីជំនួស ១ រូបផ្សេងទៀត ដែលមានលក្ខណសម្បត្តិសមស្របតាមការកំណត់របស់ក្រសួងសុខាភិបាល ។

**មាត្រា ៩.- ថ្មី**

១-ការណែនាំ និងការត្រួតពិនិត្យគ្រប់សកម្មភាព ដែលពាក់ព័ន្ធនឹងផលិតផលឱសថ ជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល ដែលត្រូវចាត់តាំងភ្នាក់ងារសុខាភិបាលឱ្យចុះត្រួតពិនិត្យសាមញ្ញ ឬវិសាមញ្ញ នៅតាមគ្រឹះស្ថានផលិតឱសថ គ្រឹះស្ថាននាំចូលឱសថ គ្រឹះស្ថាននាំចូល និងចែកចាយឱសថ គ្រឹះស្ថាននាំចេញឱសថ គ្រឹះស្ថានលក់ដុំឱសថ ឱសថស្ថាន ឱសថស្ថានរង គ្រឹះស្ថានលក់គ្រឿងសំអាង និងមធ្យោបាយដឹកជញ្ជូន ។

ក្នុងករណីចាំបាច់ ក្រសួងសុខាភិបាល មានសិទ្ធិសុំកម្លាំងអន្តរាគមន៍ ពីក្រសួង-ស្ថាប័នពាក់ព័ន្ធ ។

២-ភ្នាក់ងារសុខាភិបាលមាននីតិសម្បទា ជាមន្ត្រីនគរបាលយុត្តិធម៌ ។ បែបបទនៃការទទួលនីតិសម្បទា ជាមន្ត្រីនគរបាលយុត្តិធម៌នៃភ្នាក់ងារសុខាភិបាល ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងសុខាភិបាល និងក្រសួងយុត្តិធម៌ ។ តួនាទី និងភារកិច្ចរបស់ភ្នាក់ងារសុខាភិបាលដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងយុត្តិធម៌ស្តីពីតួនាទី ភារកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ ។

៣-ការណែនាំ និងការត្រួតពិនិត្យបសុឱសថសម្រាប់បសុព្យាបាល ជាសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ១០.- ថ្មី**

១-ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ រៀល (មួយលានរៀល) ដល់ ៥.០០០.០០០ រៀល (ប្រាំលានរៀល) ចំពោះជនណាដែលបាន :

-ផ្សព្វផ្សាយផលិតផលឱសថ និងគ្រឿងសំអាងតាមវិទ្យុ ទូរទស្សន៍ ទស្សនាវដ្តី សារព័ត៌មាន ខិតប័ណ្ណ សិក្ខាសាលា ឬ តាមមធ្យោបាយផ្សេងៗទៀត ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល

-ប្រព្រឹត្តល្មើសនឹងបែបបទ និងល័ក្ខខ័ណ្ឌក្នុងការគ្រប់គ្រងថែរក្សាផលិតផលឱសថ

-បើក បិទ ឬ ប្តូរទីតាំងឱសថស្ថាន ឱសថស្ថានរង និងគ្រឹះស្ថានលក់គ្រឿងសំអាង ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

២-ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០ រៀល (ប្រាំលានរៀល) ដល់ ១០.០០០.០០០ រៀល (ដប់លានរៀល) ចំពោះជនណាដែលបាន :

-បើក បិទ ឬ ប្តូរទីតាំងគ្រឹះស្ថានលក់ដុំឱសថ គ្រឹះស្ថាននាំចូល ចែកចាយឱសថ គ្រឹះស្ថាននាំចូល នាំចេញឱសថ ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល

-ប្រព្រឹត្តល្មើសនឹងបែបបទ និងល័ក្ខខ័ណ្ឌពាណិជ្ជកម្ម អាហារ៍ណ នីហារ៍ណឱសថ

-នាំចូល ឬ នាំចេញ ផលិតផលឱសថដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល

-ចែកចាយ តាំងលក់ ឬ បេក់ផលិតផលឱសថ និងគ្រឿងសំអាងដែលគ្មានចុះលេខទិដ្ឋាការ ឬ បញ្ជិកាពីក្រសួងសុខាភិបាល

-លក់ឱសថខូចគុណភាព និងឱសថផុតកំណត់ប្រើប្រាស់ ។

៣-ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ រៀល (ដប់លានរៀល) ដល់ ២០.០០០.០០០ រៀល (ម្ភៃលានរៀល) ចំពោះជនណាដែលបាន :

-បើក បិទ ឬ ប្តូរទីតាំងគ្រឹះស្ថានផលិតឱសថដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល

-ប្រព្រឹត្តល្មើសនឹងបែបបទ និងល័ក្ខខ័ណ្ឌបច្ចេកទេសផលិតឱសថ

-នាំចូលវត្ថុធាតុដើម ផលិតផលពាក់កណ្តាលសម្រេច សម្ភារៈវេចខ្ចប់ម៉ាស៊ីន ឧបករណ៍សម្រាប់ផលិតឱសថ ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល

-ផលិតឱសថដែលមានគុណភាព មិនត្រឹមត្រូវតាមស្តង់ដារគុណភាពក្នុងឯកសារសុំទិដ្ឋាការឱសថ

-ស្តុកវត្ថុធាតុដើម សម្ភារៈវេចខ្ចប់ ម៉ាស៊ីនឧបករណ៍ផលិត ផលិតផលឱសថក្រៅពីគ្រឹះស្ថានអាជីវកម្ម ផលិតកម្ម ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

៤-ករណីបទល្មើសខាងលើ បានបង្កឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាពសាធារណៈ ឬ អាយុជីវិតមនុស្ស សត្វ ក្រសួងសុខាភិបាលត្រូវចេញប្រកាសផ្អាកសកម្មភាពផលិត អាហរណ៍ នីហរណ៍ និងពាណិជ្ជកម្មឱសថជាបន្ទាន់ និងកសាងសំណុំរឿងបញ្ជូនទៅតុលាការដើម្បីផ្តន្ទាទោសតាមច្បាប់ ។

៥-ទោសទណ្ឌទាំងឡាយណា ដែលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០រៀល (មួយលានរៀល) ដល់ ១០.០០០.០០០ រៀល (ដប់លានរៀល) ក្រសួងសុខាភិបាលមានសិទ្ធិពិន័យអន្តរការណ៍ ។

ក្នុងករណីវិរុទ្ធជនមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ក្រសួងសុខាភិបាលត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការ ។

**មាត្រា ១១.– ថ្មី**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ខែ ទៅ ៦ខែ ឬ ផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០ រៀល (ពីរលានរៀល) ដល់ ១០.០០០.០០០រៀល (ដប់លានរៀល) ឬ ទោសទាំងពីរ ចំពោះជនណាដែលរារាំងប្រឆាំងនឹងការអនុវត្តច្បាប់នេះ ។

**មាត្រា ១២.– ថ្មី**

១-ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ ឆ្នាំ ដល់ ១០ ឆ្នាំ និង ផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០ រៀល (ម្ភៃលានរៀល) ដល់ ៥០.០០០.០០០ រៀល (ហាសិបលានរៀល) ចំពោះជនណាដែលបាន :

-ផលិត នាំចូល ឬ ស្តុកឱសថញៀន ឱសថប្រព័ន្ធសរសៃប្រសាទ សារធាតុញៀន សារធាតុផ្សំគ្រឿងញៀន ដែលកំណត់ក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឬ

ក្នុងប្រកាសរបស់ក្រសួងសុខាភិបាល ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល

-ចែកចាយ តាំងលក់ ឬ លក់ឱសថបៀន ឬ ឱសថប្រព័ន្ធសរសៃប្រសាទដែលគ្មានផលប្រយោជន៍ខាងវេជ្ជសាស្ត្រ ឬ ដែលក្រសួងសុខាភិបាលបានហាមឃាត់

-ផលិត នាំចូល ចែកចាយ តាំងលក់ ឬ លក់ឱសថក្លែងក្លាយ ។

២-ករណីបទល្មើសខាងលើ បានបង្កឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាពសាធារណៈ ឬ អាយុជីវិតមនុស្ស សត្វ ក្រសួងសុខាភិបាលត្រូវចេញប្រកាសផ្អាកសកម្មភាពផលិត អាហារិណា នីហារិណា និងពាណិជ្ជកម្មឱសថជាបន្ទាន់ និងកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីផ្តន្ទាទោសតាមច្បាប់ ។

**មាត្រា ១៣.– ថ្មី**

ត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាល ចំពោះមន្ត្រីរាជការណាដែលឃុបឃិត ឬ ប្រព្រឹត្តរំលោភលើភារកិច្ចរបស់ខ្លួន ក្នុងការអនុវត្តមាត្រា ១០ថ្មី មាត្រា ១១ថ្មី និងមាត្រា ១២ថ្មី ។ ក្នុងករណីធ្ងន់ធ្ងរត្រូវរៀបចំសំណុំរឿងបញ្ជូនទៅតុលាការ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

[illegible]

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងសុខាភិបាល
**ហត្ថលេខា**
**នុត សុខុម**

លេខ: ១៧ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ២០០៨
[illegible]រដ្ឋាភិបាល

**ឃុន ជិនកេន**